ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

*ថ្ងៃ ពុធ ១០ រោច ខែ ជេស្ឋ ឆ្នាំ មមី អដ្ឋស័ក ព.ស ២៥៧០*
*រាជធានីភ្នំពេញ, ថ្ងៃទី១០ ខែ មិថុនា ឆ្នាំ ២០២៦*

# សេចក្តីប្រកាសព័ត៌មាន
# ស្តីពីជំនួបពិភាក្សាការងាររវាង
# ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន ឧបនាយករដ្ឋមន្ត្រី
# រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
# ជាមួយ អគ្គទីប្រឹក្សាសេដ្ឋកិច្ច និងពាណិជ្ជកម្ម
# អមស្ថានទូតនៃសាធារណរដ្ឋប្រជាមានិតចិន ប្រចាំព្រះរាជាណាចក្រកម្ពុជា

នាព្រឹកថ្ងៃទី ១០ ខែ មិថុនា ឆ្នាំ ២០២៦, នៅទីស្តីការក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ, ឯកឧត្តម អគ្គបណ្ឌិតសភាចារ្យ **អូន ព័ន្ធមុនីរ័ត្ន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ បានទទួលជួបពិភាក្សាការងារជាមួយលោកជំទាវ ZHONG Jie, អគ្គទីប្រឹក្សាសេដ្ឋកិច្ច និងពាណិជ្ជកម្ម អមស្ថានទូតនៃសាធារណរដ្ឋប្រជាមានិតចិន ប្រចាំនៅព្រះរាជាណាចក្រកម្ពុជា ក្នុងឱកាសដែលលោកជំទាវបានបញ្ចប់បេសកកម្មការងារនៅប្រទេសកម្ពុជា និងជម្រាបលានា ក៏ដូចជាទទួលជួបសម្តែងការគួរសមជាមួយឯកឧត្តម XUE Dong, អគ្គទីប្រឹក្សាសេដ្ឋកិច្ច និងពាណិជ្ជកម្មថ្មី អមស្ថានទូតនៃសាធារណរដ្ឋប្រជាមានិតចិន ប្រចាំនៅព្រះរាជាណាចក្រកម្ពុជា ។

**ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ ឧបនាយករដ្ឋមន្ត្រី** បានសម្តែងការកោតសរសើរ និងថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅជូនចំពោះ**លោកជំទាវ** ZHONG Jie អគ្គទីប្រឹក្សាសេដ្ឋកិច្ច និងពាណិជ្ជកម្ម ដែលបានបំពេញការងារប្រកបដោយប្រសិទ្ធភាព និងសកម្ម ជំរុញកិច្ចសហប្រតិបត្តិការទ្វេភាគី កម្ពុជា-ចិន ទទួលបាននូវលទ្ធផលផ្លែផ្កាជាច្រើន នាពេលកន្លងមក ។ កម្ពុជា-ចិន, ក្នុងនាមភាពជាដៃគូយុទ្ធសាស្ត្រគ្រប់ជ្រុងជ្រោយ និងជាមិត្តដែកថែប, បានពូនជ្រុំទំនាក់ទំនងនៃប្រទេសទាំងពីរកាន់តែរឹងមាំពីមួយថ្ងៃទៅមួយថ្ងៃ ។ ជាក់ស្តែង, ក្នុងរយៈពេល ៥ ឆ្នាំ ចុងក្រោយនេះ, ក្នុងអំឡុងពេលដែលកម្ពុជាជួបប្រទះនូវវិបត្តិនានាចាប់ពីវិបត្តិនៃការរីករាលដាលនៃជំងឺកូវីដ ១៩ រហូតដល់វិបត្តិនាពេលថ្មីៗនេះជាបន្តបន្ទាប់, រដ្ឋាភិបាលនៃសាធារណរដ្ឋប្រជាមានិតចិន, តាមរយៈហិរញ្ញប្បទានសហប្រតិបត្តិការ, បានបន្តជួយជ្រោមជ្រែង តាមរយៈជំនួយមនុស្សធម៌បន្ទាន់ ក៏ដូចជា ការចូលរួមចំណែកដល់ការអភិវឌ្ឍលើវិស័យអាទិភាពសំខាន់ៗរបស់រាជរដ្ឋាភិបាលកម្ពុជា ជាពិសេសក្នុងវិស័យហេដ្ឋារចនាសម្ព័ន្ធ, ធារាសាស្ត្រ, ផ្លូវជនបទ, ទឹកស្អាត, ថាមពល, សុខាភិបាល, អប់រំ, និងការ

អភិវឌ្ឍធនធានមនុស្ស ជាដើម ។ ទំហំវិហូរវិនិយោគ, ទេសចរណ៍ និងពាណិជ្ជកម្មពីប្រទេសចិនក៏មានការកើនឡើងជាបន្តបន្ទាប់ពីមួយឆ្នាំទៅមួយឆ្នាំ ។

**លោកជំទាវអគ្គទីប្រឹក្សា** បានសម្តែងការវាយតម្លៃខ្ពស់ចំពោះកិច្ចសហប្រតិបត្តិការដ៏ល្អកន្លងមក ទាំងក្នុងក្របខណ្ឌទ្វេភាគី កម្ពុជា-ចិន, ភាពជាដៃគូយុទ្ធសាស្ត្រគ្រប់ជ្រុងជ្រោយ និងក្នុងក្របខណ្ឌពហុភាគីរួមមាន៖ ក្របខណ្ឌអាស៊ាន និងអង្គការពាណិជ្ជកម្មពិភពលោក ។ កិច្ចសហប្រតិបត្តិការកម្ពុជា-ចិន បានធ្វើឱ្យទំនាក់ទំនងកម្ពុជា-ចិន កាន់តែខ្លាំងក្លា និងតាមរយៈទំនាក់ទំនងនេះ បានធ្វើឱ្យការអភិវឌ្ឍសេដ្ឋកិច្ច និងសង្គមកម្ពុជាសម្រេចបានលទ្ធផលជាផ្លែផ្កាជាច្រើន ។ **លោកជំទាវអគ្គទីប្រឹក្សា** ក៏បានសម្តែងនូវការត្រេកអរផងដែរ ដែលក្នុងអំឡុងពេលបំពេញបេសកកម្មនៅកម្ពុជា **លោកជំទាវ** បានសម្រេចនូវសមិទ្ធផលធំៗជាច្រើន ក្នុងនោះរួមមាន មហាវិថី **ស៊ី ជីនពីង** (ផ្លូវក្រវ៉ាត់ក្រុងទី ៣), គម្រោងសាងសង់ផ្លូវជាតិលេខ ៧ និងគម្រោងអភិវឌ្ឍន៍សាកលវិទ្យាល័យក្រចេះជំហានទី ២ ជាដើម ។ **លោកជំទាវអគ្គទីប្រឹក្សា** សង្ឃឹមថាកម្ពុជា-ចិន នឹងបន្តពង្រឹង និងពង្រីកកិច្ចសហការលើវិស័យផ្សេងទៀត ដែលរដ្ឋាភិបាលនៃសាធារណរដ្ឋប្រជាមានិតចិន កំពុងផ្តោតការចាប់អារម្មណ៍ និងមានភាពជាយុទ្ធសាស្ត្រ ដូចជា វិស័យបច្ចេកវិទ្យា, កសិកម្ម និងពាណិជ្ជកម្ម ។

នាឱកាសនោះផងដែរ, **ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ ឧបនាយករដ្ឋមន្ត្រី**ក៏បានសម្តែងនូវការស្វាគមន៍យ៉ាងកក់ក្តៅចំពោះ ឯកឧត្តម XUE Dong អគ្គទីប្រឹក្សាសេដ្ឋកិច្ច និងពាណិជ្ជកម្មថ្មី ដែលនឹងត្រូវបន្តបេសកកម្មការងារនៅប្រទេសកម្ពុជា និងបានស្នើឯកឧត្តម XUE Dong បន្តគាំទ្រ និងជំរុញកិច្ចសហប្រតិបត្តិការទ្វេភាគី កម្ពុជា-ចិន ឱ្យទទួលបានសមិទ្ធផលជាបន្តបន្ទាប់ទៀត ក្នុងនោះ បន្តគាំទ្រជាពិសេសដល់គម្រោងជាប្រវត្តិសាស្ត្ររបស់កម្ពុជាគឺ គម្រោងគ្រប់គ្រងធនធានទឹកចម្រុះហ្វូណនតេជោ និងគម្រោងពាក់ព័ន្ធនានា ។

ឯកឧត្តម XUE Dong **អគ្គទីប្រឹក្សាថ្មី** បានមានប្រសាសន៍បន្ថែមថា **ឯកឧត្តម**មានការត្រេកអរចំពោះការអភិវឌ្ឍដ៏គួរឱ្យកត់សម្គាល់របស់ប្រទេសកម្ពុជា និងសន្យាថា ក្នុងបេសកកម្មការងាររបស់**ឯកឧត្តម**នៅប្រទេសកម្ពុជា, **ឯកឧត្តម**នឹងបន្តជំរុញកិច្ចសហប្រតិបត្តិការទ្វេភាគី កម្ពុជា-ចិន និងក្នុងនាមដៃគូយុទ្ធសាស្ត្រគ្រប់ជ្រុងជ្រោយឱ្យកាន់តែខ្លាំងក្លា និងទទួលបានលទ្ធផលកាន់តែប្រសើរឡើងថែមទៀត ។

ជាថ្មីម្តងទៀត, **ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ ឧបនាយករដ្ឋមន្ត្រី** បានថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅ និងជូនពរ **លោកជំទាវអគ្គទីប្រឹក្សា** និង**ឯកឧត្តមអគ្គទីប្រឹក្សាសេដ្ឋកិច្ច និងពាណិជ្ជកម្មថ្មី ព្រមទាំងសហការី** សូមទទួលបានសុខភាពល្អ និងជោគជ័យគ្រប់ភារកិច្ចក្នុងអាណត្តិការងារនាពេលអនាគតខាងមុខ ៕